**JobAccess**
**Driving disability employment**

# បណ្ណព័ត៌មាន
# ការជ្រើសរើសបុគ្គលិកជាជនពិការឲ្យធ្វើការ

ការជួលជនពិការអោយធ្វើការ មានគុណប្រយោជន៍ពាណិជ្ជកម្ម —
ផលប្រយោជន៍ទាំងនោះមានលើសពីការគ្រាន់តែបំពេញឲ្យមានអ្នកធ្វើការ ។
គុណប្រយោជន៍ទាំងនោះត្រូវបានអះអាងដោយមានការសិក្សាស្រាវជ្រាវនៅប្រទេសអូស្ត្រាលី និងអន្តរជាតិ ។
បុគ្គលិកដែលមានពិការភាពមានលក្ខណៈ ៖

- គួរជាទីទុកចិត្ត - ជនដែលមានពិការភាព ឈប់សម្រាកតិចជាង សុំច្បាប់ឈឺតិចជាង ហើយនិងមានកំរិតនៅធ្វើការជាប់ក្នុងស្ថាប័នមួយយូរជាងបុគ្គលិកដ៏ទៃៗទៀត ។
- មានផលិតភាព - នៅពេលដែលជនពិការត្រូវគេដាក់នៅកន្លែងការងារមួយដែលត្រូវនឹងសមត្ថភាពរបស់ពួកគេ ពួកគេបំពេញការងារបានល្អដូចបុគ្គលិកដ៏ទៃៗទៀតដែរ ។
- មិនអស់ប្រាក់ច្រើន - ការចំណាយលើការរើសបុគ្គលិក ថ្លៃសេវាធានារ៉ាប់រង និងប្រាក់សំណងផ្សេងៗគឺអស់តិចជាង។ ជនដែលមានពិការភាពមានការទាមទារប្រាក់សំណងពីឧបត្តិហេតុនិងគ្រោះថ្នាក់ផ្សេងៗនៅទីកន្លែងការងារ តិចជាងបើប្រៀបធៀបទៅនឹងបុគ្គលិកផ្សេងៗទៀត ។
- ល្អសំរាប់អាជីវកម្ម - មនុស្សដែលមានពិការភាពមានទំនាក់ទំនងរឹងមាំជាមួយអតិថិជន និងលើកកម្ពស់សីលធម៌ ភាពស្មោះត្រង់របស់បុគ្គលិក ដោយជួយបង្កើតកំលាំងការងារមួយដែលមានលក្ខណៈសំបូរបែប ។ ការចំណេញពិតប្រាកដ មានតាមរយៈការថយចុះនៃការផ្លាស់ប្តូរបុគ្គលិក ការចំណាយលើកការរើសបុគ្គលិកថ្មី និងលើការរក្សាបុគ្គលិក ។ ការជួលជនដែលមានពិការភាពឲ្យធ្វើការ ចូលរួមបង្កើតភាពចម្រុះសំបូរបែបរបស់ស្ថាប័នលោកអ្នក។ វាលើកកម្ពស់កិត្តិយសក្រុមហ៊ុនចំពោះមុខបុគ្គលិករបស់ខ្លួន អតិថិជន និងសហគមន៍ ដោយនាំមកនូវផលប្រយោជន៍ជាវិជ្ជមានដល់ឈ្មោះក្រុមហ៊ុនរបស់និយោជក ។ ការក្លាយជាស្ថាប័នដែលគិតគូរដល់ជនពិការ ជាវិធីល្អមួយដើម្បីផ្សព្វផ្សាយមុខជំនួញរបស់លោកអ្នក ។

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

**1800 464 800** **www.jobaccess.gov.au**

## ការគ្រប់គ្រងការលាតត្រដាងព័ត៌មាន

បុគ្គលិករបស់អ្នកអាចជ្រើសរើស ប្រសិនបើពួកគេចង់ ប្រាប់អ្នកអំពីពិការភាពរបស់ពួកគេ។ ច្បាប់ពុំមានបង្ខំអោយពួកគេលាតត្រដាងព័ត៌មានអំពីពិការភាពរបស់ពួកគេឡើយ ដរាបណាវាមិនប៉ះពាល់ដល់លទ្ធភាពបំពេញការងាររបស់គេ ។

ព័ត៌មានស្តីពីពិការភាពរបស់បុគ្គលិក តែងតែមានព័ត៌មានផ្ទាល់ខ្លួនលំអិតផ្សេងៗទៀតរបស់គេ ។ ប្រសិនបើបុគ្គលិកណាមួយប្រាប់អ្នកអំពីពិការភាពរបស់គេ អ្នកត្រូវតែគិតគូរពីលទ្ធភាពនៃការបណ្តុះបណ្តាល ឬធ្វើការកែប្រែផ្សេងៗទាក់ទងនឹងការងារដោយសមរម្យ ដើម្បីឆ្លើយតបនឹងតម្រូវការនានាដែលទាក់ទងនិងការងាររបស់គេ ។

## ភាពអាចបត់បែននៅទីកន្លែងការងារ

ភាពអាចបត់បែនក្នុងការរៀបចំរបៀបធ្វើការ អាចជួយធ្វើអោយស្ថាប័នរបស់អ្នកទាក់ទាញ និងរក្សាបុគ្គលិករួមទាំងអ្នកដែលមានពិការភាពផងដែរ ។

ប្រសិនជាអ្នកត្រូវការធ្វើការផ្លាស់ប្តូរផ្សេងៗលើទីកន្លែងការងារ ឬទិញសំភារៈពិសេសៗសំរាប់បុគ្គលិកដែល មានពិការភាព ការចំណាយរបស់អ្នកអាចនឹងរ៉ាប់រងចេញដោយមូលនិធិឧបត្ថម្ភការងារ (Employment Assistance Fund) (EAF) ។

ប្រសិនជាអ្នកចង់បានព័ត៌មានបន្ថែមស្តីអំពីសេវាទាំងនេះ អ្នកអាចមើលទំព័រ JobAccess នៅ www.jobaccess.gov.au ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់ JobAccess តាមរយៈលេខ 1800 464 800 - ការទាក់ទងតាមទូរសព្ទ័ដៃត្រូវគេគិតថ្លៃ។